# ការពិនិត្យឡើងវិញនូវសិលាចារឹក K.១២៤១ (Ka.៤)

សិលាចារឹកនេះរកឃើញនៅចន្លោះភូមិក្រាំងតូច និងភូមិក្រាំងធំ ស្រុកអង្គរបុរី ខេត្តតាកែវ និងដឹកជញ្ជូនមកកាន់សារមន្ទីរជាតិ នៅឆ្នាំ១៩៩៣ ដោយលោកសាស្ត្រាចារ្យ **សឺន ស៊ូប៉ែរ្ត៍**។ នៅពេលរកឃើញ សិលាចារឹកនេះបាក់បែកជាបួនផ្នែក ក្រោយមកបានជួសជុលដោយសារមន្ទីរជាតិ និងបច្ចុប្បន្នតម្កល់នៅរោងជាងជួសជុលថ្មនៃសារមន្ទីរជាតិ។ សិលាចារឹកនេះមានលេខបញ្ជីសារពើភណ្ឌសិលាចារឹក **Ka.៤** និង **K.១២៤១**។

សិលាចារឹកនេះចារនៅលើថ្មស្រទាប់ មានប្រវែង ១៤៥ស.ម. x ៧៤ស.ម. x ១៤ស.ម.។[១] ជាទូទៅយើងសង្កេតឃើញថា ចំណារអក្សរមានសភាពច្បាស់ និងជ្រៅល្អ ប៉ុន្តែដោយសារសិលាចារឹកនេះបាក់ជាបួន ហើយរកឃើញតែបីផ្នែកទើបធ្វើឱ្យបាត់អក្សរនៅផ្នែកខាងស្តាំត្រង់បន្ទាត់ទី១ដល់ទី៣។ ត្រង់ផ្នែកចារឹកអក្សរខ្លះ ថ្មបានរបេះបាត់ដោយការបាក់នៃសិលាចារឹកនោះ នាំឱ្យបាត់បង់ចំណារអក្សរ ជាពិសេសត្រង់ផ្នែកកណ្តាលបន្ទាត់ទី៤ និងទី៥។ ឯផ្នែកខ្លះទៀត ទោះថ្មស្រទាប់បានរបេះ ក៏នៅសល់ចំណារពក់ៗដែលអាចអាននៅលើថ្មបាន ប៉ុន្តែពិបាកនឹងផ្តិតជាប់នៅលើក្រដាសសំណៅផ្តិត។

កន្លងមក សិលាចារឹកនេះធ្លាប់បានសិក្សា និងចុះផ្សាយរួចមកហើយដោយលោកស្រីបណ្ឌិត **ពៅ សាវរស** នៅក្នុងសៀវភៅសិលាចារឹកថ្មីៗនៃប្រទេសកម្ពុជា ក្បាលទី២និងទី៣ (Nouvelles inscriptions du Cambodge II & III) កាលពីឆ្នាំ២០០១។ បន្ទាប់មកលោក **ហ្វីលីព ជេន្នើរ** បានយកការចុះផ្សាយរបស់លោកស្រីបណ្ឌិត **ពៅ សាវរស** ទៅចុះផ្សាយក្នុងគេហទំព័រភាសាអាស៊ីអាគ្នេយ៍[២] ដោយមានសេចក្តីប្រែជាភាសាអង់គ្លេសនិងការសិក្សាបែបភាសាវិទ្យាទៅលើអត្ថបទនោះផងដែរ។

ដោយសារក្រដាសសំណៅផ្តិតសិលាចារឹកដែលលោកស្រីបណ្ឌិត **ពៅ សាវរស** ទទួលបានពុំច្បាស់ល្អ ទើបនាំឱ្យអំណានសិលាចារឹកនេះត្រង់ផ្នែកខ្លះខ្វះខាតនិងផ្នែកខ្លះទៀតខុស។

---

[១] Saveros 2001: 188។

[២] http://sealang.net/ok/corpus.htm។

អត្ថបទដោយៈ ហ៊ុន ឈុនតេង

រីឯអំណានសិលាចារឹកនេះរបស់លោក **ហ្វីលីព ជេនឡឺរ** ក៏ពុំមានអ្វីប្លែកពីលោកស្រីបណ្ឌិត **ពៅ សាវរស** ដែរ។ ដោយសារមានឱកាសបានផ្ទៀងផ្ទាត់សិលាចារឹកនេះម្តងទៀតនៅលើថ្ម និងបានរកឃើញនូវចំណុចដែលអ្នកសិក្សាទាំងពីររូបបានអានភាន់ច្រឡំ និងខ្វះខាតទើបយើងសម្រេចចិត្តសិក្សាសិលាចារឹកនេះឡើងវិញ និងចុះផ្សាយនៅទីនេះ។

សិលាចារឹកនេះចុះកាលបរិច្ឆេទនៅមហាសករាជឆ្នាំ៦៧៨ ១៣កើត ខែវិសាខ ត្រូវនឹងគ្រិស្តសករាជឆ្នាំ៧៥៦។ លោកស្រីបណ្ឌិត **ពៅ សាវរស** អានកាលបរិច្ឆេទសិលាចារឹកនេះថាត្រូវនឹងមហាសករាជឆ្នាំ៦៩៨។ បើយើងប្រៀបធៀបនឹងសិលាចារឹកសម័យមុនអង្គរដទៃទៀត (K.១៣៨: ២២, K.១៣៧: ១៧, K.១៥៥II: ៣១) តួលេខទីពីរជាតួលេខ «៧» យ៉ាងប្រាកដពុំមែនជាតួលេខ «៩» ឡើយ។

តាមការពិនិត្យមើលអត្ថបទនេះ ទំនងជាចារមិនទាន់ចប់សព្វគ្រប់នៅឡើយទេ ដ្បិតសេចក្តីនៅក្នុងបន្ទាត់ខាងចុងបំផុត ពុំមែនជាឃ្លាបញ្ចប់នោះឡើយ។ ជារួមអត្ថបទសិលាចារឹកនេះ ចារឹកពីព្រះរាជបញ្ជារបស់ព្រះមហាក្សត្រមួយអង្គនាសម័យចេនឡាដែលពុំមានបង្ហាញព្រះនាមត្រាស់បង្គាប់ឱ្យរៀបចំប្រាសាទព្រះស្រីមុខលិង្គ នៅឯតំបន់គ្រាង ប្រហែលជាប្រគល់ឱ្យក្រុម «**យមហាសិត**» ជាអ្នកគ្រប់គ្រង។ បន្ទាប់មកមានបង្ហាញពីការរៀបចំក្រុមបាទមូល អ្នកបម្រើរបស់ក្រុមបាទមូល និងក្រុមយមហាសិត ព្រមទាំងរៀបចំព្រាហ្មណ៍ធ្វើផ្ទះនៅប្រាសាទនោះផងដែរ។ កាល **ម្រតាញនាគបាល** ជាភាគវត គឺបានឆ្លាក់បត្រ(សិលាចារឹកនេះ) និងមានសាក្សីចូលរួមមានឋានន្តរនាមជា **ម្រតាញ បោញ ចាស់ស្រុក** និង**តុលាការ**។ បន្ទាប់មកជាបញ្ជីថ្វាយស្រូវម្តៃមួយ និងក្អប់មាសមួយថ្វាយដល់ព្រះ។ ចុងក្រោយជាបញ្ញត្តដល់ជនណាដែលដកហូតសិទ្ធគេ ហើយយកអ្នកបម្រើព្រះពីប្រាសាទ អ្នកនោះនឹងត្រូវទទួលទោស។

អត្ថបទដោយៈ ហ៊ុន ឈុនតេង

## អត្ថបទដើមជាអក្សរពុម្ពបុរាណ



## អត្ថបទដើមជាអក្សរខ្មែរទំនើប

១- ៦៧៨[៣]គកបរិគ្រហត្រយោទគីពេចិ◌ៃ[វគាខ][៤] ---[នក្សត្រ]---

២- អាជ្ញាធូលី[៥]ជេង៍វ្រះកំម្រតាង៍[៦]អញ្ញិឱយ---------

៣- ក្មោញយមហាសិត្ត តគិនោះកាលម្រតាញកុរុង៍វ៊ិ[បិ/ហិ][៧]----[ប៉ុរ][៨]តេលិធូលី◌[ជង៍]

---

[៣] Saveros (2001) អានជា "៦៩[៨]"។

[៤] បន្ទាប់ពីពាក្យ "ពេច" យើងឃើញមានស្រៈ "◌ៃ" ដែលអាចសន្និដ្ឋានបានថាជាពាក្យ "វៃគាខ" ឬ "ចៃត្រ"។ យើងយល់ថាជាពាក្យ "វៃគាខ" ច្រើនជាង ដោយសារទំហំតូចនៃស្រៈ "◌ៃ" សមនឹងប្រើជាមួយអក្សរ "វ" ច្រើនជាងអក្សរ "ច"។

[៥] Saveros (2001) អានជា "ធុលិ"។

[៦] Saveros (2001) អានជា "កម្រតាង៍" ប៉ុន្តែអក្សរនៅលើផ្ទាំងថ្ម យើងឃើញច្បាស់ថាមានស្រៈ «◌ំ» នៅលើអក្សរ "ក"។

[៧] Saveros (2001) អានជា "វិធិ...." ប៉ុន្តែអក្សរនៅលើផ្ទាំងថ្ម យើងឃើញថាអក្សរខាងចុងពុំអាចជាអក្សរ "ធ" ឡើយ ប៉ុន្តែអាចជាអក្សរ "ប" ឬ "ហ"។

[៨] Saveros (2001) ពុំបានអានត្រង់នេះទេ។

អត្ថបទដោយៈ ហ៊ុន ឈុនតេង

៤- ឞ្រះកំម្រតាងអញ[៩]--------ង[១០]តាញ៑សូវិន្ទយ[១១] តាង[អញ៑][១២]---------

៥- ---◌ិ◌ែ ◌្វ-◌ារ៊[ប្រេ][១៣] ----------------ឱយិតឞ្រះកំម្រតាងអញ៑[១៤]

៦- [គ្រី]មុខលិង្គ[១៥]អាយិគ្រាង[១៦]បាទមូល [បោញ៑][១៧]ភាគាន្ត[១៨][បោ]ញ៑អា[១៩]កុលបោញ៑វិជយនទិ[២០]

៧- គិ[២១]តបំរេតគិវគ្គ៌យមហសិតទងគេបាទមូលផោងគិតទារិត្នោរិកុហ្វត្តរោំ[២២]អាច្ឆនិ

៨- កុអម្ទុតរិម[២៣]កុកន្វាញ៑វាកន្ទិព្រាហ្មណ[២៤]តប្ដុះត្វេងម្រតាញ៑នាពាយស្វាមិឧបក[២៥]

៩- ម្រតាញ៑រត្និជយគិតប្ដុះតនោះកាលម្រតាញ៑នាគបា[ល ភា]គវតគិតច្វក្ក[២៦]នេះ

---

[៩] Saveros (2001) អានជា "កម្រតាងអញ៑" ប៉ុន្តែអក្សរនៅលើផ្ទាំងថ្ម ឃើញច្បាស់ថាមានស្រៈ «◌ំ» នៅលើអក្សរ "ក" និងពុំមានសញ្ញាវិរាមលើអក្សរ "ញ" ឡើយ។

[១០] Saveros (2001) ពុំបានអានត្រង់នេះ។

[១១] Saveros (2001) អានជា "សុវិជយា"។

[១២] Saveros (2001) អានជា "តាញ៑..."។

[១៣] Saveros (2001) ពុំបានអានត្រង់នេះទេ។

[១៤] Saveros (2001) អានជា "កម្រតាងអញ៑" ប៉ុន្តែអក្សរនៅលើផ្ទាំងថ្ម យើងឃើញច្បាស់ថាមានស្រៈ "◌ំ" នៅលើអក្សរ "ក" និងពុំមានសញ្ញាវិរាមនៅលើ "ញ"ទេ។

[១៥] Saveros (2001) អានជា "ឞ្រះធូលិជេង"។

[១៦] Saveros (2001) អានជា "ប្រង" ប៉ុន្តែអក្សរនៅលើផ្ទាំងថ្ម យើងឃើញច្បាស់ថាមានស្រៈ "គ្រាង"។

[១៧] Saveros (2001) ពុំបានអានត្រង់នេះទេ។

[១៨] Saveros (2001) អានជា "អាគន្ត"។

[១៩] Saveros (2001) ពុំបានអានត្រង់នេះទេ។

[២០] បន្ទាប់ពីពាក្យ "វិជយនទិ" Saveros (2001) ដាក់សញ្ញា "--" បញ្ជាក់ថាមានពាក្យត ប៉ុន្តែតាមការពិនិត្យលើផ្ទាំងថ្ម ពុំមានពាក្យតទេ។

[២១] Saveros (2001) ពុំបានអានត្រង់នេះទេ។

[២២] Saveros (2001) ពុំបានអានត្រង់ពាក្យ "រោំ" នេះទេ ដោយលោកស្រីបណ្ឌិតដាក់សញ្ញា "---"។

[២៣] Saveros (2001) អានជា "កុ---និម" ។

[២៤] Saveros (2001) អានជា "វាកណ្ឌិព្រាហ្មណ"។

[២៥] Saveros (2001) អានជា "ទង" ប៉ុន្តែតាមអក្សរនៅលើថ្មយើងអានបានជា "ឧបក" មកពីពាក្យ "ឧបាក" មានន័យថា រួមគ្នា ចូលគ្នា។

[២៦] តាមអក្សរចារនៅលើថ្ម យើងអាចអានម្យ៉ាងទៀតជា "ប្វក្ក"។

អត្ថបទដោយៈ ហ៊ុន ឈុនតេង

១០- បត្រសាក្ស៊ិ[២៧]ម្រតាញ៑ឥគាន[២៨]គណ្ឌ[២៩]ម្រតាញ៑សាង៑[៣០]ម្រតាញ៑ជេម្ឋកុលម្រតាញ៑កន្ទេង៑[៣១]

១១- ម្រតាញ៑កុលវន្ទ[៣២]ម្រតាញ៑តាង៑កល្បិត៑[៣៣]បោញ៑រត្នវិគេម[៣៤]គ្រាមវ្ទូសកាអ្វ[៣៥]

១២- និ--ិ---ិស្រុ[៣៦]កយ៑មោយ៑ក្ទបិមាស៑មោយ៑តវ្រះកំម្រតាង៑[៣៧]អញ៑គេហ្វត្តនា

១៣- តន្ត្រតោ[៣៨]យ៑គេតកថាមនិអ្នកវ្រះលេយ៑គេតេល៑ឱយ៑ទណ្ឌ

១៤- [វ្រះ]ក[ន្ទោ]ញ៑អំវីតគិនេះកាល[៣៩] [---ចន្ទោះទទេ---]

## អត្ថបទប្រែសម្រួល

(១-៣) ឆ្នាំ៦៧៨មហាសករាជ ថ្ងៃទី១៣រោច ខែពិសាខ ព្រះអាជ្ញាធូលីជើងព្រះកម្ដែងអញបង្គាប់ឱ្យ---ក្ញោយមហាសិត្ត។

(៣-៦) ដ៏គឺកាលនោះម្រតាញកុរុងវិបិ--បុរៈដែលធូលីជើងព្រះកម្ដែងអញ---តាញសូរិន្ទយ តាងអញ---ប្រើ---ថ្វាយដល់ព្រះកម្ដែងអញស្រីមុខលិង្គនៅឯគ្រាង។

(៦-៧) បាទមូលមានបោញគាសាន្ត បោញអាកុល បោញវិជ័យនន។

[២៧] Saveros (2001) អានជា "----សាក៑គិ"។

[២៨] Saveros (2001) អានជា "ត្លៀគានា" ។

[២៩] Saveros (2001) អានជា "គណ្ឌា" ។

[៣០] Saveros (2001) អានជា "សង៑" ។

[៣១] បន្ទាប់ពីពាក្យ "កន្ទេង៑" Saveros (2001) ដាក់សញ្ញា "--" បញ្ជាក់ថាមានពាក្យត។

[៣២] Saveros (2001) អានជា "កុលវន្ទិ"។

[៣៣] Saveros (2001) អានជា "----តាញ៑កល្បិត៑"។

[៣៤] Saveros (2001) អានជា "រត្នវិកេម" និងបន្ទាប់ពីពាក្យនេះដាក់សញ្ញា "--------" បញ្ជាក់ថាមានពាក្យត។

[៣៥] Saveros (2001) អានជា "ស-----វ្វូ"។

[៣៦] Saveros (2001) អានជា "--------"។

[៣៧] Saveros (2001) អានជា "កម្រតាង៑អញ៑"។ នៅលើផ្ទាំងចារឹក អ្នកចារជួស "ម្រ" នៅខាងលើចន្លោះ "កំ" និង "តាង៑"។

[៣៨] Saveros (2001) ពុំបានអានត្រង់នេះទេ។

[៣៩] Saveros (2001) បញ្ជាក់ថានៅបន្ទាត់ទី១៤ អក្សរមើលពុំច្បាស់។

អត្ថបទដោយៈ ហ៊ុន ឈុនតេង

(៧-៨) អ្នកបម្រើដល់ក្រុមយមហាសិតនិងអ្នកបម្រើដល់បាទមូលផងដែលទទួលជាថ្វូរ មានកុហ្វត្តវ៉ោះអាច្ចន កុអម្រឹតពិស កុកន្ទាញ វាកន្ទិ ព្រាហ្មណ៍។

(៨-៩) ព្រាហ្មណ៍ដែលធ្វើផ្ទះគឺតម្ងើងឱ្យម្រតាញនាពយស្វាមី រួមទាំងកម្រតាញរស្មិជ័យគឺជាផ្ទះនៅទីនោះ។

(៩-១១) កាលម្រតាញនាគបាលជាភាគវតគឺធ្លាក់(សិលាចារឹក)នេះ(អ្នកជា)បត្រសាក្សីមានម្រតាញឥសានគណ ម្រតាញសាង ម្រតាញជេស្ឋកុល ម្រតាញកន្មេង ម្រតាញកុលវន្ទ ម្រតាញតាងកល្បិត បោញរត្នវិសេស ចាស់ស្រុក សភា(តុលាការ)---។

(១២) ស្រូវម្តែមួយ ក្អប់មាសមួយថ្វាយដល់ព្រះគម្តែងអញ។

(១២-១៣) អ្នកហូតយកកន្ទែងគេគ្រប់គ្រងដោយថាខ្លួនជាអ្នកមានអ្នកបម្រើព្រះអ្នកនោះត្រូវទទួលទោស។

(១៤) ព្រះកន្ទោញអំពីនេះកាល---។

## ឯកសារយោង


Saveros, Pou.

2001. *Nouvelles Inscriptions du Cambodge II-III.* EFEO. Paris.


KHMER CIVILIZATION

## បញ្ជីរូបភាព



សំណៅផ្តិតសិលាចារឹក K.១២៤១ (រូបថត៖ សមុច្ច័យសារមន្ទីរជាតិ)



រូបថតសិលាចារឹក K.១២៤១ (រូបថត៖ សមុច្ច័យសារមន្ទីរជាតិ)

អត្ថបទដោយ៖ ហ៊ុន ឈុនតេង